៣-ឯកឧត្តម សៅ សុខា មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ជា សមាជិក

៤-ឯកឧត្តម នេត សាវឿន ប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ជា សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចដូចតទៅ :

-ស្រាវជ្រាវគ្រប់មូលហេតុអោយបានល្អិតល្អន់ ចំពោះបាតុភាពដែលកើតមានឡើងចំពោះយន្តហោះ ដែល ត្រូវជូនព្រះរាជដំណើរ នៅព្រឹកថ្ងៃទី០១ ខែសីហា ឆ្នាំ២០០០ នេះ

-មានសិទ្ធិកោះអញ្ជើញគ្រប់សមាសភាពពាក់ព័ន្ធមកបំភ្លឺ

-រាយការណ៍ពីលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល

-មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ

-អនុប្រធាន និងសមាជិកទាំងអស់ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី
ហត្ថលេខានិងត្រា
ហ៊ុន សែន

***

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

## សេចក្តីសំរេច លេខ ៥១ សសរ
## ស្តីពី
## ការបង្កើតគណៈកម្មការចំរុះ កម្ពុជា-បែលហ្ស៊ិក

***

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

-យោងតាមសំណើរបស់ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**សំរេច**

ប្រការ ១ : បង្កើតគណៈកម្មការចំរុះ កម្ពុជា-បែលហ្ស៊ិក ដែលមានសមាសភាពដូចខាងក្រោមនេះ :

១-ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ប្រធាន

២-ឯកឧត្តម អ៊ុជ គីមអន រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៣-ឯកឧត្តម ខុង សំនួន អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

-តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

-តំណាង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

-តំណាង ក្រសួងអប់រំ យុវជន និងកីឡា សមាជិក

-តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក

-តំណាង ក្រសួងសុខាភិបាល សមាជិក

-តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

-តំណាង ក្រសួងសាធារណការនិងដឹកជញ្ជូន សមាជិក

-តំណាង ក្រសួងការពារជាតិ សមាជិក

-តំណាង ក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ សមាជិក

-ប្រធាននាយកដ្ឋានអឺរុប នៃក្រសួងការបរទេស សមាជិក ទទួលបន្ទុកលេខាធិការ

ប្រការ ២ : គណៈកម្មការចំរុះនេះមានបេសកកម្ម :

-ពិចារណាបញ្ហាដែលកើតមានឡើង ក្នុងអំឡុងពេលនៃការអនុវត្តកិច្ចព្រមព្រៀង រវាងរាជរដ្ឋាភិបាលបែលហ្ស៊ិក និងរាជរដ្ឋាភិបាលកម្ពុជា ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យអប់រំ សុខាភិបាល អភិវឌ្ឍន៍ ជនបទ គមនាគមន៍ ការកាត់រំសាយកងទ័ព និងការកាត់បន្ថយអាវុធធុនស្រាល ។

ប្រការ ៣ : ដើម្បីបំពេញបេសកកម្មខាងលើ គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិ :

-បង្កើតប្រតិទិនប្រចាំឆ្នាំមួយ សំរាប់អនុវត្តគំរោងផែនការ ដែលភាគីទាំងពីរបានឯកភាព ។

-ធ្វើរបាយការណ៍ជូនប្រមុខរាជរដ្ឋាភិបាល ដើម្បីស្នើសុំគោលការណ៍ ឬមតិណែនាំ ។

-សមាជិកនៃគណៈកម្មការ ត្រូវចូលរួមប្រជុំការងារ តាមការអញ្ជើញរបស់ប្រធាន ។

-មានសិទ្ធិប្រើត្រា របស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្នុងការអនុវត្តនីភារកិច្ចពាក់ព័ន្ធចាំបាច់ ។

ប្រការ ៤ : ក្រសួងស្ថាប័ននីមួយៗ ត្រូវបញ្ជូនឈ្មោះនិងមុខងារនៃតំណាងរបស់ខ្លួន ដូចមានចែងក្នុងប្រការ១ មកប្រធានគណៈកម្មការចំរុះនេះ ដើម្បីងាយស្រួលក្នុងការបំពេញភារកិច្ចរបស់គណៈកម្មការ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អគ្គលេខាធិការ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍ជនបទកម្ពុជា ប្រធានក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន

***

## ៣- សេចក្តីប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីប្រកាស

### សេចក្តីប្រកាស លេខ ០៣ ប្រក

### របស់រាជរដ្ឋាភិបាល

### ស្តីពីការអភិវឌ្ឍន៍ដំណាំកៅស៊ូគ្រួសារនៅកម្ពុជា

* * *

កៅស៊ូធម្មជាតិ គឺជាដំណាំកសិ-ឧស្សាហកម្ម ដែលបានផ្តល់ផលប្រយោជន៍យ៉ាងសំខាន់ សំរាប់សេដ្ឋកិច្ចជាតិ ។ ជារៀងរាល់ឆ្នាំ ប្រទេសកម្ពុជាបានស្រូបយករូបិយប័ណ្ណយ៉ាងច្រើនដែលបានមកពីការនាំចេញផលិតផលកៅស៊ូធម្មជាតិ ។

ប្រទេសកម្ពុជាមានដីក្រហម និងដីប្រភេទផ្សេងៗទៀតគាប់សែនហិតពាដែលមានសក្តានុពលអាចដាំដុះកៅស៊ូបាន ប៉ុន្តែរហូតមកទល់បច្ចុប្បន្ននេះ យើងនៅពុំទាន់បានប្រើប្រាស់អោយអស់សក្តានុពលនេះនៅឡើយ ។